# ផ្នែកទី III ( ii )
# ផ្លាកសញ្ញាប្រាប់ ទីប្រជុំជន និង ព្រំប្រទល់តំបន់
## ( Buildup Area and Boundary Signs )

ផ្លាកសញ្ញាប្រាប់ ទីប្រជុំជន មានរាងជាចតុកោណកែង ដែលមានជ្រុងដេកវែងជាងជ្រុងឈរ មានស៊ុំក្រៅពណ៌ស ស៊ុំក្នុងពណ៌ក្រហម ផ្ទៃពណ៌ស និង អក្សរខាងក្នុងដែលជាឈ្មោះរបស់ទីប្រជុំជន ពណ៌ខ្មៅ ។ ផ្លាកសញ្ញាប្រភេទនេះសំរាប់ ប្រាប់អ្នកបើកបរ អោយបានដឹង ពីចំណុចចាប់ផ្តើម នៃទីប្រជុំជន ។ ក្នុងករណីស៊ុំខាងក្នុងប្តូរពីពណ៌ក្រហមទៅជាពណ៌ខ្មៅ និង មានឆ្នូតក្រហមកាត់ ពីកំពូលក្រោមខាងឆ្វេង ទៅកំពូលលើខាងស្តាំ ប្រាប់ពីចំណុច បញ្ចប់ ទីប្រជុំជន ។

សញ្ញាប្រាប់ ព្រំប្រទល់តំបន់ មានរាងជាចតុកោណកែង ដែលមានជ្រុងដេកវែងជាងជ្រុងឈរ ដូចគ្នាដែរ តែមានស៊ុំក្រៅ ពណ៌ស ផ្ទៃពណ៌ខៀវ និង អក្សរខាងក្នុងដែលជាឈ្មោះព្រំប្រទល់ ភូមិ ឃុំ-សង្កាត់ ស្រុក-ខ័ណ្ឌ ឬខេត្ត-ក្រុង ពណ៌ស ។ ផ្លាកសញ្ញាប្រភេទនេះសំរាប់ ប្រាប់អ្នកបើកបរអោយបានដឹង ពីទីកន្លែងដែលគេបានមកដល់ ឬ ចាកចេញ ក្នុងករណីដែលឃើញមាន ឆ្នូតក្រហមកាត់ ពីកំពូលក្រោមខាងឆ្វេងទៅកំពូលលើខាងស្តាំ ។

## ផ្នែកទី III ( ii ) : ផ្លាកសញ្ញាប្រាប់ ទីប្រជុំជន និង ព្រំប្រទល់តំបន់
## ( Buildup Area and Boundary Signs )




**ទីប្រជុំជន**

BUILD UP AREA

**លេខកូដ : PW03-G2-01**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ប្រាប់ អោយអ្នកបើកបរ ដឹង អំពីការចូលមកដល់ ទីប្រជុំជន ។

---




**ចប់ ទីប្រជុំជន**

END BUILD UP AREA

**លេខកូដ : PW03-G2-02**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ប្រាប់ អោយអ្នកបើកបរ ដឹង អំពីការ ចប់ ទីប្រជុំជន ។







**ព្រំប្រទល់ ខេត្ត ស្រុក ឬ ឃុំ**

PROVINCIAL, DISTRICT OR COMMUNE BOUNDARY

**លេខកូដ : PW03-G2-03**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ប្រាប់ អោយអ្នកបើកបរដឹង អំពីការ ចូលមកដល់ ព្រំប្រទល់ ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ឬ ឃុំ-សង្កាត់។

---







**ចប់ ព្រំប្រទល់ ខេត្ត ស្រុក ឬ ឃុំ**

END PROVINCIAL, DISTRICT OR COMMUNE BOUNDARY

**លេខកូដ : PW03-G2-04**

**ខ្លឹមសារ** : សញ្ញានេះ ប្រើសំរាប់ប្រាប់ អោយអ្នកបើកបរដឹង អំពីការ ចប់ ព្រំប្រទល់ ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ឬ ឃុំ-សង្កាត់ ។